# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាជាមួយអង្គីធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលី ម៉ាតាំង
# ព្រៃធំ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩
# គ្រួសារដែលទុកចិត្តលើឧបការគុណរបស់ព្រះជាម្ចាស់

**អត្ថបទទី១៖ ថេស្សាឡូនិក ទី១ ៤,១៣-១៨**

ប្រសិនបើយើងជឿថា ព្រះយេស៊ូពិតជាបានសោយទិវង្គត ហើយមានព្រះជន្មរស់ឡើងវិញមែន យើងក៏ជឿថា ព្រះជាម្ចាស់នឹងនាំបងប្អូនដែលបានស្លាប់ទៅហើយ ឲ្យទៅនៅជាមួយព្រះអង្គ ដោយសារព្រះយេស៊ូដែរ។ ១ថស ៤,១៤

**ដំណឹងល្អ៖ លូកា ៤,១៦-៣០**

ព្រះវិញ្ញាណរបស់ព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ព្រះអង្គបានចាក់ប្រេងអភិសេកខ្ញុំ ឲ្យនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ។ ព្រះអង្គបានចាត់ខ្ញុំឲ្យមកប្រកាសប្រាប់ ជនជាប់ជាឈ្លើយថា គេនឹងមានសេរីភាព ហើយប្រាប់មនុស្សខ្វាក់ថាគេនឹងមើលឃើញវិញ។ ព្រះអង្គបានចាត់ខ្ញុំឲ្យមករំដោះអស់អ្នកដែលត្រូវគេសង្កត់សង្កិន ព្រមទាំងប្រកាសអំពីឆ្នាំដែលព្រះអម្ចាស់ សម្តែងព្រះហឫទ័យមេត្តាករុណា»។ លក ៤,១៨-១៩

បងប្អូនជាទីស្រឡាញ់!

នៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ យើងបានស្វាគមន៍ធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលី អស់ពីដួងចិត្ត អស់ពីសេចក្តីស្រឡាញ់ កន្លែងខ្លះយើងបានធ្វើអគ្គសញ្ញាជ្រមុជទឹក កន្លែងខ្លះយើងបានធ្វើអគ្គសញ្ញាលាបថ្ងាស អរិយក្សត្រយើងបានធ្វើអគ្គសញ្ញាអាពាហ៍ពិពាហ៍ ម្សិលមិញនៅចំប៉ា យើងបានរៀបចំព្រះពរសម្រាប់គ្រួសារដែលបានរៀបការពីយូរឆ្នាំហើយ។ យើងបានធ្វើដំណើរជាមួយគ្នានៅក្នុងសេចក្តីសុខ ណែនាំឲ្យធាតុទាំង២នាក់ប្តីប្រពន្ធដូចជាបានផ្តល់កម្លាំង ផ្តល់ជំនឿ និងសេចក្តីស្រឡាញ់ថែមទៀតសម្រាប់គ្រួសារនីមួយៗ។

ល្ងាចនេះ ខ្ញុំចង់និយាយអំពីឧបការគុណរបស់ព្រះជាម្ចាស់ អម្បាញមិញយើងបានស្តាប់នៅក្នុងអត្ថបទទី១ លោកប៉ូលគាត់រំលឹកដល់គ្រីស្តបរិស័ទ "**យើងត្រូវតែជាស់តឿនគ្នាទៅវិញទៅមក ដោយដឹងថាព្រះយេស៊ូយាងមកដើម្បីណែនាំឲ្យមនុស្សស្លាប់ទទួលជីវិតអស់កល្បជានិច្ច និងមនុស្សនៅរស់អាចចូលនៅក្នុងស្ថានបរមសុខដែរ**"។ ប្រសិនបើ យើងគិតអំពីជីវិតយើងនៅលើផែនដីនេះ នៅពេលនេះយើងពោរពេញដោយសេចក្តីសង្ឃឹម ទៅលើពាក្យសន្យារបស់ព្រះជាម្ចាស់ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងយើងទាំងគ្នាចូលនៅក្នុងជីវិតថ្មីនៅស្ថានបរមសុខជាមួយព្រះជាម្ចាស់នៅថ្ងៃអនាគត។ ប្រសិនបើ យើងនិយាយអំពីគម្រោងការណ៍របស់ព្រះជាម្ចាស់សម្រាប់យើងនៅផែនដីនេះ យើងបានស្តាប់នៅក្នុងអត្ថបទគម្ពីរដំណឹងល្អអម្បាញមិញ "**ព្រះ**

**យេស៊ូចូលមកក្នុងធម្មសាលា ព្រះអង្គចាប់ផ្ដើមទេសនា ឲ្យនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ ព្រះអង្គបានចាត់ខ្ញុំដើម្បីប្រកាស ដល់អ្នកដែលជាប់មន្ទីរឃុំឃាំងថាគេនឹងមានសេរីភាព អ្នកដែលខ្វាក់គេនឹងមើលឃើញ អ្នកដែលដើរមិនបានគេនឹងដើរបាន**"។ បើយើងនិយាយសង្ខេប គម្រោងការណ៍ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់សម្រាប់មនុស្សយើង គឺព្រះជាម្ចាស់បានបង្កើតយើងជាបុរសជាស្ត្រីឲ្យមានជីវិត និងឲ្យយើងមានសុភមង្គលលើផែនដីនេះ និងមានសេចក្តីសុខអស់កល្បជានិច្ចនៅស្ថានបរមសុខ។ យើងអាចទទួលសុភមង្គលនៅផែនដី និងសេចក្តីសុខនៅស្ថានបរមសុខ លុះត្រាតែយើងទុកចិត្តទុកដាក់ទៅលើឧបការគុណរបស់ព្រះជាម្ចាស់។

ឧបការគុណរបស់ព្រះជាម្ចាស់ មានន័យយ៉ាងម៉េច? ហ្សឺលី គាត់ពន្យល់យើងហើយដោយនិយាយថា "**ជារៀងរាល់ថ្ងៃ ខ្ញុំផ្ញើជីវិតរបស់ខ្ញុំទៅលើព្រះជាម្ចាស់ ដោយដឹងថាព្រះជាម្ចាស់ដឹងយ៉ាងច្បាស់អំពីសេចក្តីត្រូវការរបស់ខ្ញុំ**"។ ទាំង២នាក់មានកូនច្រើន ដើម្បីបង្កើតគ្រួសារមួយដ៏សុខសាន្តដោយភ្ជាប់ជាមួយព្រះជាម្ចាស់ ពេលភ្ញាក់ពីដេកភ្លាមគេណែនាំឲ្យកូនៗរបស់គេដោយនិទានរឿងអំពីព្រះយេស៊ូ នៅពេលគាត់ពាក់អាវឲ្យកូនម្ដាយនិទានរឿងព្រះយេស៊ូឲ្យកូនៗគាត់ស្ដាប់ រួចហើយគេអធិដ្ឋានជាលក្ខណៈគ្រួសារ នៅម៉ោង៥កន្លះគេចូលអភិបូជាជារៀងរាល់ថ្ងៃ។ ខ្ញុំគិតថានៅទីនេះជាកន្លែងពិសេសដោយសារនៅព្រះសហគមន៍យើងនៅទីនេះ យើងមានក្រុមគ្រួសារយើងមានលោកតាលោកយាយ យើងមានឪពុកម្ដាយ យើងមានកូនៗ យើងមានយុវជន នេះជាក្រុមគ្រួសារមួយៗដែលត្រូវតែយកចិត្តទុកដាក់ ដើម្បីឲ្យកូនៗស្គាល់ព្រះយេស៊ូ ដើម្បីឲ្យគេរស់នៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់ក្នុងផ្ទះរបស់យើង។ នៅតាមផ្ទះនីមួយៗ យើងមានរូបព្រះនាងម៉ារី សន្តយ៉ូសែប ព្រះយេស៊ូ ដូច្នេះនេះជាឱកាសមួយជារៀងរាល់ថ្ងៃ ដើម្បីអធិដ្ឋានជាលក្ខណៈគ្រួសារ និងយកចិត្តទុកដាក់ចូលអភិបូជាពីព្រឹកដើម្បីទទួលកម្លាំងសម្រាប់ពេញមួយថ្ងៃ ដោយដឹងថាព្រះជាម្ចាស់ថែរក្សាយើង។

យើងមានជីវិតធម្មតាដូចគ្រួសារ ហ្សឺលី និង លូវីស ដែល លូវីស គាត់ធ្វើជាងនាឡិកា ហ្សឺលី គាត់នៅផ្ទះគាត់ចាក់អាវប៉ាក់អាវ មើលកូន ធ្វើការងារផ្ទះ ដោយនឹកឃើញព្រះជាម្ចាស់ស្រឡាញ់យើង ថែរក្សាយើងជានិច្ច។ ដូច្នេះ ពីមួយថ្ងៃទៅមួយថ្ងៃគេមានជីវិតធម្មតា សម្អាតផ្ទះ ធ្វើម្ហូប ទៅផ្សារ ប៉ុន្តែយកចិត្តទុកដាក់ដោយថែរក្សាកូនជានិច្ច។ យប់ឡើងគេជួបជុំគ្នាជាលក្ខណៈគ្រួសារមុនចូលដេកដើម្បីអធិដ្ឋាន និងអរព្រះគុណព្រះជាម្ចាស់សម្រាប់ពេញមួយថ្ងៃ សុំទោសព្រះជាម្ចាស់សម្រាប់អំពើបាបដែលយើងបានប្រព្រឹត្ត និងសូមព្រះអង្គប្រទានពរឲ្យគ្រួសាររបស់យើងសម្រាកយ៉ាងស្រួលនៅក្នុងសេចក្តីសុខរបស់ព្រះជាម្ចាស់។ ជាគ្រួសារមួយដែលយកចិត្តទុកដាក់នឹងកូន ជាគ្រួសារមួយដែលរកឃើញសុភមង្គល ដោយសារគេផ្ញើជីវិតទៅលើឧបការ

គុណរបស់ព្រះជាម្ចាស់។ លូវីស ចង់ធ្វើជាបូជាចារ្យធ្វើមិនបាន ហ្សេលី ចង់ធ្វើជាបងស្រីធ្វើមិនបាន នៅពេលគេជួបគ្នាគេយល់ថាព្រះជាម្ចាស់បានរៀបចំគម្រោងការណ៍ ឲ្យគេទាំង២ជួបជុំគ្នារៀបការជាមួយគ្នា ដើម្បីបង្កើតគ្រួសារដែលមានកូនយ៉ាងច្រើន។ នៅពេលកូនគាត់៤នាក់បានស្លាប់ សម្រាប់ ហ្សេលី នៅពេលគាត់មានផ្ទៃពោះជូនកាលគាត់ភ័យ តើកូនខ្ញុំនៅរស់អត់? នៅពេល ហ្សេលី គាត់ដឹងថា៦ខែទៀតគាត់នឹងស្លាប់ដោយកូនគាត់នៅក្មេងខ្ចី នៅពេលនោះគាត់ពិបាកចិត្ត គាត់ឈឺចិត្ត ម្តាយដែលជិតស្លាប់ដោយចោលកូននៅលើផែនដីនេះឈឺចិត្តណាស់ ក៏ប៉ុន្តែគាត់ដឹងថាព្រះជាម្ចាស់ថែរក្សាគ្រួសារគាត់ និងព្រះជាម្ចាស់ផ្តល់កម្លាំងដើម្បីឲ្យឆ្លងផុតឧបសគ្គនិងទុក្ខលំបាក។

ដូច្នេះ នេះជាសញ្ញាសម្គាល់ ជាបទពិសោធន៍យ៉ាងជាក់ស្តែង អំពីរបៀបដែលគ្រួសារ លូវីស បានរស់នៅជាលក្ខណៈគ្រួសារធម្មតា ប៉ុន្តែយកព្រះជាម្ចាស់ជាអាទិភាពដោយដឹងថាអត់មានព្រះជាម្ចាស់យើងទៅមុខមិនបាន អត់មានព្រះជាម្ចាស់យើងរកឃើញសុភមង្គលមិនបាន។ មានតែព្រះជាម្ចាស់ដែលថែរក្សាយើង និងប្រទានសេចក្តីសង្ឃឹមឲ្យយើងបាន។ ខ្ញុំអញ្ជើញឪពុកម្តាយស្តាប់គ្នាទៅវិញទៅមក លើកទឹកចិត្តគ្នាទៅវិញទៅមក ចេះស្រឡាញ់គ្នាទៅវិញទៅមក លើកលែងទោសឲ្យគ្នាទៅវិញទៅមក។ ខ្ញុំអញ្ជើញកូនៗឲ្យស្តាប់ឪពុកម្តាយដែលអប់រំណែនាំ ស្តាប់លោកតាលោកយាយដែលអប់រំណែនាំ និងចេះស្រឡាញ់គ្នាជាបងប្អូននៅក្នុងក្រុមគ្រួសារផ្ទាល់ខ្លួន។ ខ្ញុំសូមអញ្ជើញលោកតាលោកយាយ ឲ្យធ្វើជាគំរូនិងដឹកនាំក្រុមគ្រួសារដើម្បីឲ្យគ្រួសារនីមួយៗអាចទៅមុខនៅក្នុងសង្គមបច្ចុប្បន្ននេះដែលជាសង្គមថ្មី យើងត្រូវការថែរក្សាវត្តមានរបស់ព្រះជាម្ចាស់។ លោកតាលោកយាយ ដែលមានជំនឿលើព្រះជាម្ចាស់សូមជួយលើកទឹកចិត្ត អប់រំណែនាំផ្តល់កម្លាំងឲ្យកូនចៅ ឲ្យគេស្រឡាញ់ព្រះយេស៊ូ ព្រះនាងម៉ារី សន្តយ៉ូសែប។ កុំភ្លេចព្រះសហគមន៍តូចបំផុត មិនមែនព្រះសហគមន៍របស់យើងជាមួយបងស្រី បងប្រុស បូជាចារ្យ ដែលដឹកនាំ ព្រះសហគមន៍តូចបំផុតនិងអស្ចារ្យបំផុត គឺព្រះសហគមន៍ដែលជាគ្រួសាររបស់យើង។ គ្រួសាររបស់យើង ជាព្រះសហគមន៍ដ៏តូចមួយ ដែលចេះស្រឡាញ់ព្រះជាម្ចាស់ ដែលចេះស្រឡាញ់គ្នាទៅវិញទៅមកដើម្បីបង្កើតសេចក្តីសុខ។ ដូច្នេះ ប្រសិនបើគ្រួសារនីមួយៗជាព្រះសហគមន៍ដ៏តូចមួយ ដែលចេះស្រឡាញ់ព្រះជាម្ចាស់ ចេះស្រឡាញ់គ្នាទៅវិញទៅមក ព្រះសហគន៍ដ៏ធំរបស់យើងនឹងអាចរីកចម្រើន នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គពិតមែន។

នៅពេលនេះ យើងអធិដ្ឋានដើម្បីសូមព្រះជាម្ចាស់ប្រទានសេចក្តីសង្ឃឹមនៅក្នុងជីវិតយើង ឲ្យយើងផ្ញើសេចក្តីសង្ឃឹមរបស់យើងទៅលើព្រះជាម្ចាស់ ដោយសារព្រះជាម្ចាស់មានឧបការគុណសម្រាប់ជីវិតយើងពិតមែន និងណែនាំឲ្យយើងទៅជាមហាគ្រួសាររបស់ព្រះអង្គនៅថ្ងៃណា

មួយចូលស្ថានបរមសុខ រួមជាមួយសន្ត លូវីស សន្តី ហ្សេលី សន្តី តេរេសា និងសន្តសន្តីទាំងឡាយ។ ជយោសន្ត លូវីស ជយោសន្តី ហ្សេលី ជយោសន្តី តេរេសា នៃព្រះកុមារយេស៊ូ។ អាម៉ែន៕